ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៚៚៚

តុលាការកំពូល
៚៚

សំណុំរឿង ព្រហ្មទណ្ឌ
លេខ: ៥៩
ចុះថ្ងៃទី០៣ - ៩ - ៩៩
សាលដីកា
លេខ:៣៣
ចុះថ្ងៃទី២៧ - ១០ - ៩៩

# តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៩ ដោយមានសមាសភាពដូចតទៅ :

១ - ឯកឧត្តម ឌិត មុន្ទី ជាប្រធាន
២ - លោក ឈឹម ស៊ីផល ចៅក្រម
៣ - លោក សោម សិរីវឌ្ឍ ចៅក្រម
៤ - លោក ប្រាក់ គឹមសាន ចៅក្រមរបាយការណ៍
៥ - លោក យស់ សូខឿន ចៅក្រម

លោក ប៉ុល វិណ្ណា ក្រឡាបញ្ជី
តំណាងមហាអយ្យការលោក សាយ សារី ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្ដឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ ២៣៣ ចុះថ្ងៃទី០១ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ និង សំណុំរឿងព្រហ្មទណ្ឌលេខ ៥៩ ចុះថ្ងៃទី០៣ខែ កញ្ញាឆ្នាំ ១៩៩៩ របស់តុលាការកំពូល

ពីបទ: ក្លែងបន្លំលិខិតឯកជន ប្រព្រឹត្តកាលពីថ្ងៃទី ២៥ - ០២ - ៩៩ នៅក្រុងព្រះសីហនុ បទល្មើសដែលមានចែងតាមបញ្ញត្តិមាត្រា ៥០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ។

- ជនជាប់ចោទឈ្មោះ មាស វិណ្ណារី " ជាម្ចាស់បណ្ដឹងសាទុក្ខ " ភេទស្រីអាយុ ៣០ឆ្នាំ ជាតិខ្មែរ កើតនៅស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម របររកស៊ី លក់ដូរ មានទីលំនៅមុនពេលចាប់ខ្លួន ផ្ទះសង់ថ្មី សង្កាត់ប្រាំងចំរេះ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ មាស មុត " ស " ម្ដាយឈ្មោះ យិន សាន " ស " ប្ដីឈ្មោះ តាំង សេងលី ។ នៅក្នុងឃុំ ។

មេធាវីលោក ប៉ូច ឆេងតិច

- ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ប៉ុក ង៉ា " ជាចុងបណ្ដឹងសាទុក្ខ " ភេទស្រី អាយុ៦៣ឆ្នាំ ជាតិខ្មែរ មានទីលំនៅសព្វថ្ងៃផ្ទះលេខ ៥អ៊០ សង្កាត់បឹងរាំង ខណ្ឌដូនពេញ ក្រុងភ្នំពេញ ។

មេធាវី គ្មាន

- តាមបណ្ដឹងសាទុក្ខលេខ ៧៩ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់លោកប៊ិច - រិទ្ធិកា មេធាវីជនជាប់ចោទ ដែលប្ដឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ២៣៣ ចុះថ្ងៃទី០១ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្ដីសំរេចទាំងមូល ។

តាមពាក្យបណ្ដឹងចុះថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ១៩៩៩ របស់ឈ្មោះ ប៉ុក ង៉ោ ប្ដឹងពីឈ្មោះ មាស វណ្ណារី ពីបទ ក្លែងស្នាមមេដៃលើលិខិតផ្ទេរសិទ្ធិ ចុះថ្ងៃទី ២៨-០២-៩៩ ដោយអាងហេតុថា ខ្លួនពុំបានផ្ទេរសិទ្ធិអោយទៅឈ្មោះ មាស វណ្ណារី ឡើយ ។

- បានឃើញសេចក្ដីសំរេចឃុំខ្លួនលេខ ៦៣៩ តព្រ ចុះថ្ងៃទី ២៩ ខែកក្កដា ឆ្នាំ ១៩៩៩ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងព្រះសីហនុ ។

- បានឃើញសេចក្ដីសំរេចលេខ ៦៦៣តព្រចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៩ របស់តុលាការក្រុងព្រះសីហនុ បានសំរេច :

១ - លើកពាក្យបណ្ដឹងសុំធានាឈ្មោះ មាស វណ្ណារី អោយនៅក្រៅឃុំជាបណ្ដោះអាសន្ន ចុះថ្ងៃទី ៣០-៧-៩៩ របស់លោក ប៊ិច រិទ្ធិកា ជាមេធាវី ។

២ - បន្តការឃុំខ្លួនមាស វណ្ណារី នៅពន្ធនាគារក្រុងព្រះសីហនុដើម្បីអង្កេតតាមច្បាប់ ។

- បានឃើញបណ្ដឹងឧទ្ធរណ៍លេខ ៣៧ ចុះថ្ងៃទី ០៩-៨-៩៩ របស់លោកប៊ិច រិទ្ធិកា មេធាវី ជនជាប់ចោទ ដែលប្ដឹងតវ៉ាពីសេចក្ដីសំរេចលេខ ៦៦៣តព្រចុះថ្ងៃទី ០៦-៨-៩៩ របស់តុលាការ ក្រុងព្រះសីហនុ លើសេចក្ដីសំរេចទាំងមូល ។

- បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា សូមតម្កល់សេចក្ដី សំរេចរបស់តុលាការក្រុងព្រះសីហនុ និងបន្តការឃុំខ្លួនជនជាប់ចោទបន្តទៀត ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ២៣៣ ចុះថ្ងៃទី០១ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់ សាលាឧទ្ធរណ៍ដែលបានសំរេច:

១ - ទទួលពាក្យបណ្ដឹងឧទ្ធរណ៍របស់លោក ប៊ិច រិទ្ធិកា មេធាវីជនជាប់ចោទចុះថ្ងៃទី - ០៩-៨-៩៩ មានលក្ខណៈត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២ - តម្កល់សេចក្ដីសំរេចលេខ ៦៦៣តព្រចុះថ្ងៃទី០៦-៨-៩៩ របស់តុលាការក្រុង ព្រះសីហនុ ទុកជាបានការទាំងមូល ។

៣ - សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខមេធាវីជនជាប់ចោទ កំបាំងមុខជនជាប់ចោទ ចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី មានប្រសិទ្ធិភាពអនុវត្តភ្លាមៗ ទោះមានបណ្ដឹង សាទុក្ខក៏ដោយ ។

- បានឃើញបណ្ដឹងសាទុក្ខលេខ ៧៩ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់លោក ប៊ិច រិទ្ធិកា មេធាវីជនជាប់ចោទ ដែលប្ដឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ២៣៣ ចុះថ្ងៃទី ០១ ខែ - កញ្ញា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្ដីសំរេចទាំងមូល ។

- បានឃើញសារណាចុះថ្ងៃទី ១០ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់អ្នកស្រីមាស វណ្ណារី ជាម្ចាស់បណ្ដឹងសាទុក្ខ ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ ។

- បានឃើញសារណាតបចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ១៩៩៩ របស់អ្នកស្រី ប៉ុក ង៉ោ ជាចុងបណ្ដឹងសាទុក្ខ ធ្វើឡើងត្រឹមត្រូវតាមកំណត់ច្បាប់ ។

- បានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

- បានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលថា: ការដោះលែងជនជាប់ចោទនាង មាស វណ្ណារី អោយនៅក្រៅឃុំជាបណ្ដោះអាសន្ន ពុំមានការប៉ះពាល់ធ្ងន់ធ្ងរដល់ការស៊ើបអង្កេតទេ ។ មហាអយ្យការសូមធ្វើសេចក្ដីសន្និដ្ឋានដូចខាងក្រោម:

១ - បណ្ដឹងសាទុក្ខរបស់មេធាវីការពារជនជាប់ចោទ ស្ថិតនៅក្នុងកំណត់ច្បាប់ គប្បីលើកយករឿងនេះ មកពិនិត្យពិចារណា ។

២ - ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ ២៣៣ ចុះថ្ងៃទី ០១-៩-៩៩ របស់សាលាឧទ្ធរណ៍ ។

- បានស្ដាប់សារណារបស់ជនជាប់ចោទ នាពេលសវនាការ

- បានស្ដាប់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនាពេលសវនាការថា: ខ្ញុំបានទៅប្រទេសបារាំងព្យាបាលជំងឺ ខ្ញុំពុំដែលធ្លាប់ស្គាល់ឈ្មោះ មាស វណ្ណារី នេះទេ ហើយខ្ញុំក៏ពុំដែលបានខ្ចីចងការប្រាក់គេដែរ នាងខ្ញុំសូមពរសុំអោយតុលាការ បន្តឃុំខ្លួនឈ្មោះ មាស វណ្ណារី បន្តទៀត ។

- បានស្ដាប់សេចក្ដីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទនាពេលសវនាការថា: ក្នុងរឿងនេះបទល្មើសមិនជាក់ស្ដែង ម្យ៉ាងទៀតអ្នកដែលពាក់ព័ន្ធឈ្មោះ ចាន់ រដ្ឋរិទ្ធិ បានស្លាប់បាត់ទៅហើយ ។ កូនក្ដីខ្ញុំបាទមានអ្នកធានាត្រឹមត្រូវ មានផ្ទះសម្បែងពិតប្រាកដ ហើយមានទ្រព្យសម្បត្តិដែលអាចធានាថា មិនរត់គេចវេសឡើយ ។

អាស្រ័យហេតុនេះសូមតុលាការអនុញ្ញាត អោយកូនក្ដីខ្ញុំបាទបាននៅក្រៅឃុំបណ្ដោះអាសន្ន ដោយក្ដីអនុគ្រោះ ។

- ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានស្ដាប់សារណារបស់ជនជាប់ចោទ ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងសេចក្ដីសន្និដ្ឋានការពារ របស់មេធាវីជនជាប់ចោទ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថា បណ្ដឹងសាទុក្ខលេខ ៧៩ ចុះថ្ងៃទី ០១-៩-៩៩ របស់លោក ប៊ិច រិទ្ធិកា មេធាវីការពារអោយឈ្មោះ មាស វណ្ណារី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿង-នេះមកជំនុំជំរះបានតាមមាត្រា ១៤ នៃច្បាប់ស្ដីពីការចាត់តាំងនិងសកម្មភាពរបស់សាលាជំរះក្ដី ។

- យល់ឃើញថា ការដែលតុលាការក្រុងព្រះសីហនុ និង សាលាឧទ្ធរណ៍សំរេចលើកពាក្យសុំធានានាឈ្មោះ មាស វណ្ណរី អោយនៅក្រៅឃុំជាបណ្ដោះអាសន្នចុះថ្ងៃទី ៣០-៧-៩៩ របស់មេធាវីលោក ប៊ិច រិទ្ធិកា ដោយអាងហេតុថាការដោះលែងឈ្មោះ មាស វណ្ណរី អាចបង្កការលំបាក និងប៉ះពាល់ដល់ការស៊ើបអង្កេតរកជនពាក់ព័ន្ធ នោះគឺជាការភាន់ច្រឡំ ពីព្រោះថាៈ

លទ្ធផលនៃការស៊ើបអង្កេតបានបង្ហាញអោយឃើញថា ជនដែលរៀបចំសំណុំបែបបទ និងលិខិតស្នាមផ្សេងៗ ទាក់ទិនក្នុងការផ្ទេរសិទ្ធិ ពីអ្នកស្រី ប៉ុក ង៉ោ មកអ្នកស្រី មាស វណ្ណរី គឺជាជនផ្សេងទៀត ដែលតុលាការបានធ្វើកំណត់ហេតុសួរចម្លើយ និងខ្លះទៀតតុលាការបានស្គាល់ច្បាស់រួចមកហើយ ។

ទោះបីមានលិខិតផ្ទេរសិទ្ធិចុះថ្ងៃទី ២៥-០២-៩៩ ក៏ពិតមែន ប៉ុន្តែលិខិតផ្ទេរសិទ្ធិដែលកើតចេញពីកិច្ចសន្យាចុះថ្ងៃទី ១៥-០២-៩៨ ពុំអាចសំរេចក្នុងការផ្ទេរសិទ្ធិដីកើតហេតុនេះបានឡើយ ដូច្នេះការដោះលែងអ្នកស្រី មាស វណ្ណរី ក៏ពុំបណ្ដាលអោយមានព្យសនកម្ម ដល់អ្នកស្រី ប៉ុក ង៉ោ ដែរៗ

- យល់ឃើញថា ជនជាប់ចោទបានធ្វើសារណាជូនមកតុលាការកំពូល និងបានទទួលដីកាកោះហើយ ប៉ុន្តែពុំបានចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះ កំបាំងមុខជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ២៣៣ ចុះថ្ងៃទី ០១-៩-៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្ដីមកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងគតិច្បាប់ ។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្ដីចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី មេធាវីជនជាប់ចោទ
កំបាំងមុខជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ

១ - ទទួលបណ្ដឹងសាទុក្ខលេខ ៧៩ ចុះថ្ងៃទី ០១-៩-៩៩ របស់លោក ប៊ិច រិទ្ធិកា មេធាវីជនជាប់ចោទ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២ - ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ ២៣៣ ចុះថ្ងៃទី០១-៩-៩៩ របស់សាលាឧទ្ធរណ៍ទាំងមូល ដោយឥតបង្វិល ។

៣ - ដោះលែងជនជាប់ចោទឈ្មោះ មាស វណ្ណរី អោយនៅក្រៅឃុំជាបណ្ដោះអាសន្នតាមពាក្យសុំ ។

៤ - បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ៥៤ ចុះថ្ងៃទី ១៩-៨-៩៩ របស់តុលាការកំពូលទៅតុលាការក្រុងព្រះសីហនុ ដើម្បីចាត់ការតាមនីតិវិធី ។

៥ - សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ១៩៩៩ ។